# អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

# មគ្គុទេសក៍ក្នុងប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា

គម្រោងអាស៊ីគូដា

កំណែ.៤.២.២២

# សេចក្ដីណែនាំ

ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា) ត្រូវបានអភិវឌ្ឍឡើងដោយសន្និសិទ្ធអង្គការសហប្រជាជាតិស្ដីពីការអភិវឌ្ឍន៍និងពាណិជ្ជកម្ម (UNCTAD) ដែលជាមធ្យោបាយនៃការចងក្រងស្ថិតិពាណិជ្ជកម្មបរទេស។

- ដើម្បីងាយស្រួលនៃនីតិវិធី
- កិច្ចសម្រួលពាណិជ្ជកម្ម
- ស្ថិតិពាណិជ្ជកម្ម
- ប្រព័ន្ធនេះប្រើប្រាស់ស្តង់ដារអន្តរជាតិទាំងអស់សម្រាប់ទិន្នន័យពាណិជ្ជកម្មក្រោមអនុសញ្ញា ISO និង WCO។
- បណ្ដា៨០ប្រទេសបច្ចុប្បន្ននេះកំពុងប្រើប្រាស់វា។

# មគ្គុទេសក៍ក្នុងប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា

## តារាងមាតិកាសង្ខេប៖

**មគ្គុទេសក៍ក្នុងប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា** ..... 0

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ..... 0

**មគ្គុទេសក៍ក្នុងប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា** ..... 2

១. កម្មវិធីប្រព័ន្ធអាស៊ីគូដា | ASYCUDA System ..... 5

២. សូមស្វាគមន៍មកកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ..... 6

២.១ របៀបប្រើប្រាស់ឧបករណ៍ផ្សេងៗក្នុងប្រព័ន្ធ ..... 6

២.២ ការចូលប្រើប្រាស់បណ្ណាល័យឯកសារ ..... 7

២.៣. បង្កើតប្រតិវេទន៍គយថ្មី ..... 7

៣.២. ប្រតិវេទន៍គយថ្មីនិងរបាររឧបករណ៍ ..... 9

៣.២.១. យល់ដឹងអំពីរបារផ្ទៀងផ្ទាត់និងចុះបញ្ជីការ ..... 10

៣.២.២. យល់ដឹងអំពីរបារនាំចេញនិងនាំចូលឯកសារ ..... 12

៣.២.៣. យល់ដឹងអំពីរបារបន្ថែមនិងលុបមុខទំនិញ ..... 15

៣.២.៤. យល់ដឹងអំពីរបារបោះពុម្ព ..... 15

៤. របៀបបំពេញព័ត៌មានទាក់ទងនិងកុងតឺន័រ ..... 16

៤.១ សម្រាប់ជាឧទាហរណ៍÷ ..... 17

# របៀបចូលទៅកាន់ប្រព័ន្ធអាស៊ីគូដា

ជាដំបូងដើម្បីចូលទៅប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា ជាដំបូងយើងត្រូវបើកកម្មវិធីអ៊ិនធើណែតណាមួយ ដើម្បីវាយបញ្ចូលនូវអាសយដ្ឋាន សូមធ្វើការណែនាំដូចខាងក្រោម÷

រូបភាពខាងក្រោមនេះមានកម្មវិធីអ៊ិនធើណែតជាច្រើន ដូច្នេះសូមរើសយកកម្មវិធីណាមួយសម្រាប់ប្រើប្រាស់

Firefox Browser Chrome Browser Internet Explorer Safari Browser

### ក. ចុចលើកម្មវិធី Firefox Browser នៅលើអេក្រង់កុំព្យូទ័រ

### ខ. បើកកម្មវិធី Firefox Browser




| No | Currency | Unit | Exchange Rate | Unit | Exchange Rate |
|---|---|---|---|---|---|
| 1 | Australian Dollar | 1 USD | 1.3978 AUD | 1 AUD | 2897.5000 KHR |
| 3 | Canadian Dollar | 1 USD | 1.3877 CAD | 1 CAD | 2918.5000 KHR |
| 4 | China Yuan Renminbi | 1 USD | 6.4490 CNY | 1 CNY | 628.0000 KHR |
| 5 | China in Hong Kong | 1 USD | 6.5323 CNH | 1 CNH | 620.0000 KHR |
| 6 | Euro ( European Union ) | 1 USD | 0.9186 EUR | 1 EUR | 4409.0000 KHR |
| 7 | Hong kong Dollar | 1 USD | 7.7143 HKD | 1 HKD | 525.0000 KHR |
| 8 | Indian rupee | 1 USD | 66.1063 INR | 1 INR | 61.2650 KHR |

បន្ទាប់ពីបើកកម្មវិធី Firefox Browser រួចមកសូមធ្វើតាមដូចខាងក្រោម÷

- វាយបញ្ចូលនូវ http://awweb.customs.gov.kh ទៅក្នុងរបារអាសយដ្ឋានរបស់កម្មវិធីអ៊ិនធើណែត
- ចុចលើរូបភាព ASYCUDA **ប្រព័ន្ធអាស៊ីគូដា** | ASYCUDA

## ១. កម្មវិធីប្រព័ន្ធអាស៊ីគូដា| ASYCUDA System

បន្ទាប់ពីចុចលើរូប ASYCUDA រួចមកវានឹងទាញយកឯកសារពីម៉ាស៊ីនបម្រើ មកដាក់ក្នុងកុំព្យូទ័ររបស់លោកអ្នក បន្ទាប់មកយើងចុចលើឯកសារនោះដើម្បីប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា   សូមមើលរូបខាងក្រោម÷




សូមរង់ចាំមួយសន្ទុះ វានឹងទាញយកឯកសារពីម៉ាស៊ីនបម្រើមកដាក់លើកុំព្យូទ័រលោកអ្នក  បន្ទាប់មកវានឹងបង្ហាញផ្ទាំងកម្មវិធីអាស៊ីគូដាមួយមក  រួចតម្រូវឱ្យលោកអ្នកវាយបញ្ចូលឈ្មោះអ្នកប្រើ និងលេខសម្ងាត់។




**<u>សម្រាប់ជាឧទាហរណ៍សូមវាយបញ្ចូល</u>÷**

- ឈ្មោះអ្នកប្រើ   :  ratha
- លេខកូដសម្ងាត់:  xxxxx

**សូមបញ្ជាក់បើសិនជាវាយលេខសម្ងាត់មិនត្រឹមត្រូវ នោះប្រព័ន្ធមិនអនុញ្ញាតឲ្យប្រើប្រាស់ទេ។**

# ២. សូមស្វាគមន៍មកកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ

បន្ទាប់ពីលោកអ្នកវាយឈ្មោះអ្នកប្រើ និងលេខសម្ងាត់ត្រឹមត្រូវ វានឹងបង្ហាញដូចរូបភាពខាងក្រោម÷




<u>កម្មវិធីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ</u>

## ២.១ របៀបប្រើប្រាស់ឧបករណ៍ផ្សេងៗក្នុងប្រព័ន្ធ




- **កម្មវិធី** Finder: លោកអ្នកអាចប្រើរបារស្វែងរកប្រតិវេទន៍តាមរបៀបកាត់នេះបាន។
- **កម្មវិធីអ៊ីម៉ែល**: យើងអាចផ្ញើអ៊ីម៉ែលទៅកាន់គ្នាទៅវិញទៅមកបាន ដោយគ្រាន់តែវាយបញ្ចូលឈ្មោះគណនីអ្នកប្រើប្រាស់ឲ្យបានត្រឹមត្រូវ រួចបញ្ចូលខ្លឹមសារអត្ថបទ។

- **កម្មវិធីបណ្ណាល័យឯកសារ:** ជាបណ្តុំឯកសារដែលយើងប្រើប្រាស់ សម្រាប់ស្វែងរកប្រតិវេទន៍ បង្កើតបែបបទបញ្ចេញទំនិញពីគយ និងផ្លាស់ប្តូរលេខសម្ងាត់អ្នកប្រើប្រាស់។
- **ម៉ឺនុយបិទកម្មវិធី:** វាជាប៊ូតុងចាកចេញពីកម្មវិធី នៅពេលដែលយើងឈប់ប្រើប្រាស់។

## ២.២ ការចូលប្រើប្រាស់បណ្ណាល័យឯកសារ




រូបភាពបណ្ណាល័យឯកសារ

## ២.៣. បង្កើតប្រតិវេទន៍គយថ្មី

ចុចលើរមូលនៃទង់ជាតិកម្ពុជា ដើម្បីពន្លាវារហូត សូមមើលរូបខាងក្រោម÷



ASYCUDA → Goods Clearance → Declaration → Detailed Declaration → Detailed Declaration

**បន្ទាប់មកទៀត សូមចុច** Mouse **ខាងស្តាំលើពាក្យ** Detailed Declaration **ជ្រើសយកពាក្យ** New




**<u>បង្កើតប្រតិវេទន៍ថ្មី</u>**

ឬម្យ៉ាងទៀតលោកអ្នកអាចចុចលើពាក្យ Detailed Declaration រួចយក Mouse ចុចលើក្រដាស ឬឧបករណ៍ស្វែងរក សូមមើលរូបភាពខាងក្រោម÷




**<u>របារផ្លូវកាត់នៃការចុចបើកប្រតិវេទន៍ថ្មី ឬស្វែងរក</u>**

ក្នុងករណីលោកអ្នកត្រូវការស្វែងរកប្រតិវេទន៍ដែលបានចុះបញ្ជីការរួចនោះ យើងត្រូវចុចលើរូបស្វែងរកប្រតិវេទន៍ តែក្នុងមេរៀនរបស់យើងគឺ បើកប្រតិវេទន៍ថ្មី ដើម្បីបំពេញបែបបទនាំចេញនាំចូលទំនិញ។

## ៣.២. ប្រតិវេទន៍គយថ្មីនិងរបារឧបករណ៍




**<u>ប្រតិវេទន៍គយថ្មីរបស់ប្រព័ន្ធអាស៊ីគូដា</u>**

***<u>សំគាល់</u>***÷ លោកអ្នកចាំបាច់ត្រូវតែយល់ដឹងនិងអត្ថន័យចំពោះប្រអប់នីមួយៗចាប់ពីប្រអប់ទី១ រហូតដល់ប្រអប់ទី៥៤ ទើបអាចបំពេញឯកសារបែបបទទំនិញនាំចេញនាំចូលបាន។ នៅក្នុងប្រតិវេទន៍គយបានចែកចេញជាបីផ្នែកធំៗ ដូចខាងក្រោម÷

**១.ផ្នែកទី១**÷ ប្រអប់ទី១ ទៅដល់ប្រអប់ទី២៨ - ផ្នែកព័ត៌មានទូទៅ របស់ក្រុមហ៊ុននាំចូលនាំចេញ ប្រភេទនៃការប្រកាសទំនិញនាំចេញនាំចូល។ល។ (SAD General Segment)

**២.ផ្នែកទី២**÷ ប្រអប់ទី៣១ ទៅដល់ប្រអប់ទី៤៦ -ព័ត៌មានទាក់ទងទៅនឹងមុខទំនិញ (Item Segment)

**៣.ផ្នែកទី៣**÷ ប្រអប់ទី៤៧ ដល់ប្រអប់ទី៤៩ - តារាងគិតពន្ធ (Taxation Base)

ដូច្នេះប្រសិនបើលោកអ្នកជាជើងសារគយ នោះលោកអ្នកប្រាកដជាយល់ដឹងពីនិតិវិធីនិងវិធីនៃការបំពេញបែបបទទំនិញពីគយ។ នៅក្នុងមេរៀននេះយើងខ្ញុំសូមមិនបង្ហាញព័ត៌មានលម្អិតដែលទាក់ទងទៅនឹងប្រអប់នីមួយៗទេ ដោយសារវាត្រូវចំណាយពេលវេលាច្រើនក្នុងការពិពណ៌នា ដូចនេះប្រសិនបើលោកអ្នកចង់បានពត៌មានលម្អិតសូមទាក់ទងមន្ត្រីគយនៅតាមមាត់ច្រក ឬមកទំនាក់ទំនងផ្ទាល់នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

## ៣.២.១. យល់ដឹងអំពីរបារផ្ទៀងផ្ទាត់និងចុះបញ្ជីការ




របារឧបករណ៍មួយចំនួនដែលលោកអ្នកត្រូវស្វែងយល់ និងប្រើប្រាស់ជាប្រចាំពេលលោកអ្នកត្រូវការបំពេញបែបបទទំនិញនៅគ្រប់មាត់ច្រក។ ដូច្នេះយើងខ្ញុំនឹងបង្ហាញវាម្តងមួយៗដូចខាងក្រោម÷




ឯកសារនេះជាឧទាហរណ៍សម្រាប់លើមកបង្ហាញ នៅពេលលោកអ្នកបានបំពេញបែបទៅក្នុងប្រតិវេទន៍រួចមក សូមចុចលើរូបភ្នែក  ដើម្បីផ្ទៀងផ្ទាត់ឯកសារ ពេលនោះប្រព័ន្ធវារត់ទៅផ្ទៀងផ្ទាត់គ្រប់៥៤ប្រអប់ ព្រមទាំងផ្ទាំងនីមួយៗប្រសិនបើវាទាមទារ។ ទោះបីជាលោកអ្នកបំពេញខុសក៏ដោយ ក៏វាមិនកែតម្រូវឲ្យត្រូវត្រឹមត្រូវដែរ ដូច្នេះសូមពិនិត្យហើយ ពិនិត្យទៀតមុនពេលចុះបញ្ជីការ។



ដើម្បីចុះលេខប្រតិវេទន៍សូមចុចលើរូប  ដូចរូបខាងលើបានបង្ហាញ បន្ទាប់មកវានឹងសួរលោកអ្នកបញ្ជាក់បន្ថែមទៀត ប្រសិនបើលោកអ្នកច្បាស់លាស់នោះ សូមចុចលើសញ្ញាធីកដើម្បីយល់ព្រម។




សូមចុចធីក ដើម្បីយល់ព្រមប្រសិនបើលោកអ្នកត្រូវការបោះពុម្ពបន្ថែមនូវជម្រើសណាមួយសូមចុចលើធីកនៃប្រអប់នីមួយៗ វានឹងបង្ហាញជូនលោកអ្នកបន្ទាប់ពីលោកអ្នកចុចលើធីកបញ្ចប់។




បន្ទាប់ពីចុចសញ្ញាធីករួចមក វានឹងបង្ហាញសារថ្មីមួយបង្ហាញថា “តើលោកអ្នកត្រូវការពិនិត្យវាឥឡូវទេ? ” នៅក្នុងប្រអប់អ៊ីម៉ែលលោកអ្នក។ ចុចធីកដើម្បីអានសារថ្មីក្នុងប្រអប់សំបុត្រ និងបង្ហាញវាម្តងទៀតដើម្បីបោះពុម្ពឯកសារដើម្បីដាក់ជូនមន្ត្រី។




សូមចុចលើផ្ទាំង Attachment (1) ដើម្បីមើលប្រតិវេទន៍រួចហើយត្រូវបោះពុម្ពឯកសារប្រតិវេទន៍ចំនួនពីរច្បាប់។ សូមបញ្ជាក់បន្ទាប់ពីលោកអ្នកមើលប្រតិវេទន៍រួចមក ប្រសិនបើមើលឃើញមានកន្លែងខ្វះខាត ឬកំហុសដោយប្រការណាមួយហើយ លោកអ្នកមិនអាចកែប្រែបានឡើយ។

## ៣.២.២. យល់ដឹងអំពីរបារនាំចេញនិងនាំចូលឯកសារ

ប្រសិនបើលោកអ្នកត្រូវការប្រកាសលេខកូដមុខទំនិញ ឬក្រុមហ៊ុននាំចូលដដែលនោះ វាជាការងាយស្រួល ហើយងរហ័សទៀតផង ដោយគ្រាន់តែផ្លាស់ប្តូរលេខយោងតែប៉ុណ្ណោះ។

សូមបញ្ជាក់ថាលោកអ្នកអាចដាក់បញ្ចូលលេខយោងសម្រាប់សំគាល់ក្រុមហ៊ុនរបស់លោកអ្នកយ៉ាងម៉េចក៏បាន តែសូមកុំឲ្យវាដូចគ្នានឹងលេខយោងចាស់នៃឯកសារប្រតិវេទន៍ដែលបានប្រកាសពីលេខយោងមុន។




សូមចុចលើរូបសញ្ញា ដើម្បីនាំចេញឯកសាររួចរក្សាទុកវាក្នុងថាសកុំព្យូទ័រឬ flash drive របស់លោកអ្នក




សូមវាយបញ្ចូល÷

- ជ្រើសរើសទីតាំងរក្សាទុកឯកសារ
- ឈ្មោះឯកសារ
- ចុចប៊ូតុង Save ដើម្បីបញ្ចប់ឯកសារ

បន្ទាប់ពីចុចលើប៊ូតុងរក្សាទុករួចមក វានឹងបង្ហាញសារថ្មីមួយទៀតដោយបញ្ជាក់ថាការនាំចេញឯកសារបាន ដោយជោគជ័យ សូមមើលរូបភាពខាងក្រោម÷




ក្នុងករណីលោកអ្នកត្រូវការនាំចូលឯកសារសូមចុចលើរូបទង់ជាតិខ្មែរនៃអាស៊ីគូដា ដើម្បីពន្លាវាចុះក្រោម ASYCUDA → Goods Clearance → Declaration → Detailed Declaration → Detailed Declaration ចុច Mouse ខាងស្តាំរួចរើសយកប្រតិវេទន៍ថ្មី ដើម្បីនាំចូលឯកសារដែលយើងបានប្រកាសពីមុខដែលយើងបាន រក្សាទុកក្នុងថាសកុំព្យូទ័រ ឬ flash drive របស់លោកអ្នក។




សូមចុចលើរូបសញ្ញា  ដើម្បីនាំចូលឯកសារដែលលោកអ្នកបានរក្សាវាទុកដូចរូបភាពខាងក្រោម÷




សូមធ្វើដូចខាងក្រោម÷

- ជ្រើសរើសទីតាំងឯកសារ
- ចុចលើឯកសារដែលបានរក្សាទុក
- ចុចលើប៊ូតុង Open ដើម្បីនាំចូលឯកសារនោះ






បន្ទាប់ពីចុចធីក្សរួចមក   រាល់ព័ត៌មានទាំងអស់នឹងត្រូវលោតចូលក្នុងប្រអប់ទាំងអស់   ដូច្នេះលោកអ្នកគ្រាន់តែបំពេញបន្ថែមឬកែតម្រូវទៅក្នុងប្រអប់ណាមួយដែលលោកអ្នកត្រូវធ្វើការប្រាស់ប្ដូរ ដូចជាកាលបរិច្ឆេទវិក័យប័ត្រ ចំណារអគ្គនាយករង ទម្ងន់សរុប ទម្ងន់សុទ្ធ ឬក៏បន្ថែមមុខទំនិញ។ល។

បន្ទាប់មកចុចលើសញ្ញាភ្នែក   វានឹងបង្ហាញកំហុសកើតឡើងព្រមជាមួយបន្ទាត់ក្រហមលិចពីក្រោមប្រអប់ (Error: The declaration already exists) មានន័យថាលោកអ្នកត្រូវផ្លាស់ប្ដូរលេខយោងផ្សេងពីនេះ ព្រោះប្រព័ន្ធមិនអនុញ្ញាតឲ្យដាក់លេខយោងដដែលនោះទេ   សម្រាប់ជាឧទាហរណ៍សូមបញ្ចូលវាតាមលំដាប់ពី LTL05 ទៅ LTL06 ។



ចុចសញ្ញាធីកដើម្បីបញ្ចប់ ប្រសិនបើលោកអ្នកប្រាកដប្រជាថាមិនត្រូវការកែប្រែអ្វីទៀតនោះ បន្ទាប់ពីនេះត្រូវចុះបញ្ជីការលើប្រតិវេទន៍នោះតែម្តង។ សូមបញ្ជាក់ក្នុងករណីលោកអ្នកចុះបញ្ជីការរួចហើយ លោកអ្នកមិនអាចកែប្រែបានឡើយ។

## ៣.២.៣. យល់ដឹងអំពីរបារបន្ថែមនិងលុបមុខទំនិញ

ប្រសិនបើលោកអ្នកត្រូវការបន្ថែមមុខទំនិញ សូមចុចលើរូបក្រដាស ដើម្បីបន្ថែមមុខទំនិញ




លោកអ្នកអាចចុចបន្ថែមមុខទំនិញបានរហូតដល់៩៩មុខ ដូច្នេះបើលោកអ្នកមានមុខទំនិញលើសពីនេះ ត្រូវតែបំបែកប្រតិវេទន៍ជាពីរ។




ក្នុងករណីលោកអ្នកត្រូវការលុបមុខទំនិញ សូមចុចលើរូបសញ្ញាខ្វែង ដើម្បីលុបមុខទំនិញ សូមបញ្ជាក់ករណីលោកអ្នកលុបមុខទំនិញលេខពីរ នោះមុខទំនិញលេខបីរំកិលឡើងជំនួសទីពីរវិញ។

## ៣.២.៤. យល់ដឹងអំពីរបារបោះពុម្ព

ដើម្បីបោះពុម្ពឯកសារសូមចុចលើរូបសញ្ញាបោះពុម្ព រួចចុចលើសញ្ញាធីក សូមមើលរូបភាពខាងក្រោម÷







## ៤. របៀបបំពេញព័តិមានទាក់ទងនិងកុងតឺន័រ

- ធីកលើប្រអប់លេខ១៩នៃប្រតិវេទន៍គយ (ប្រសិនបើយើងត្រូវប្រកាសមុខទំនិញមានកុងតឺន័រ)







**ផ្ទាំងកុងតឺន័រថ្មី**

## ៤.១ សម្រាប់ជាឧទាហរណ៍÷

មុខទំនិញខ្លះផ្ទុកកុងតឺន័រ  ដូច្នេះយើងមិនអាចវាយបញ្ចូលលេខកុងតឺន័រនៅខាងមុខដូចកំណែចាស់នៃប្រព័ន្ធអាស៊ីគូដាបានឡើយ សូមពិនិត្យមើលដូចរូបភាពខាងក្រោម÷







ផ្ទាំងបញ្ចូលលេខកុងតឺន័រ

- បញ្ចូលលេខ 1 នៅក្នុងផ្ទាំង Item
- បញ្ចូលលេខកូដកុងតឺន័រ នៅក្នុង Container No.
- ជ្រើសរើសប្រភេទនៃកុងតឺន័រដូចជា 20" ឬ 40" ហ្វីត...។ល។

បន្ទាប់មកចុច ដើម្បីបញ្ចូល Container ចូលក្នុងបញ្ជីរហូតដល់ប្រាំបីមុខ។